**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ...១៤...សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការជាតិកែទម្រង់ ការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៦ ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ :** បង្កើតគណៈកម្មការជាតិកែទម្រង់ការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ រួមមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម **ស ខេង** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ជាប្រធាន |
| ២- ឯកឧត្តម **ទៀ បាញ់** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ | ជាអនុប្រធាន |
| ៣- ឯកឧត្តម **ឯម សំអាន** | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | ជាសមាជិកទទួលបន្ទុកអចិន្ត្រៃយ៍ |
| ៤- ឯកឧត្តម **អង្គ វង្សវឌ្ឍានា** | រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ | ជាសមាជិក |
| ៥- ឯកឧត្តម **ចាយ សាំងយ៉ុន** | រដ្ឋលេខាធិការ ក្រសួងការពារជាតិ | ជាសមាជិក |
| ៦- ឯកឧត្តម **អ៊ុក រ៉ាប៊ុន** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៧- ឯកឧត្តម **ម៉ិន អ៊ុយ** | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |

www.pheakdeylaw.com

៨- ឯកឧត្តម កែ គឹមយ៉ាន អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ជាសមាជិក

៩- ឯកឧត្តម ហុក ឡុងឌី អគ្គស្នងការនគរបាលជាតិ ជាសមាជិក

**ប្រការ២ :** គណៈកម្មការជាតិកែទម្រង់ការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ មានតួនាទី ភារកិច្ចដឹកនាំកិច្ចការមួយចំនួនដូចខាងក្រោម :

- តាក់តែងលិខិតបទដ្ឋាន សម្រាប់ការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ និងពង្រឹងការអនុវត្តច្បាប់នេះឱ្យមានប្រសិទ្ធភាព ។
- កសាងផែនការសកម្មភាព ស្តីពីការប្រយុទ្ធប្រឆាំង ការរីករាលដាលនៃអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ស្របតាមច្បាប់ជាតិ និងលិខិតុបករណ៍អន្តរជាតិ ។
- បន្តកែទម្រង់ការគ្រប់គ្រងប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ក្នុងកងកម្លាំងឯកសណ្ឋាន មន្ត្រី និងស្ថាប័នសាធារណៈ ។
- ជំរុញការប្រមូលដកហូតអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ដែលនៅសេសសល់រាយប៉ាយក្រៅការគ្រប់គ្រង ។
- ពិនិត្យសម្រេចពីបរិមាណ ប្រភេទ គុណភាព នៃអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវ ដែលត្រូវបំផ្លាញចោល ។
- ទំនាក់ទំនងសហប្រតិបត្តិការជាមួយបណ្តាអង្គការ សហគមន៍ជាតិ អន្តរជាតិ និងប្រទេសនានា សំដៅស្វែងរកការគាំទ្រផ្នែកបច្ចេកទេស ថវិកា និងសម្ភារៈ ។

**ប្រការ៣ :** គណៈកម្មការជាតិកែទម្រង់ការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ មានសិទ្ធិបង្កើតលេខាធិការដ្ឋានមួយសម្រាប់ជំនួយការ និងប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ដើម្បីចាត់ចែងកិច្ចការ និងបង្កើតផ្នែកគណនេយ្យដោយឡែកសម្រាប់គ្រប់គ្រងប្រើប្រាស់ថវិកា ។

**ប្រការ៤ :** សេចក្តីសម្រេចលេខ ៤១ សសរ ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០០ ស្តីពីការបង្កើតគណៈកម្មការជាតិកែទម្រង់ការគ្រប់គ្រងអាវុធជាតិផ្ទុះនៅកម្ពុជា និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្ត ក្រុងដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ... ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com